ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កោះកន្ទាយ
## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | ៖ កោះកន្ទាយ |
| ភូមិ | ៖ ជាំធំ |
| ឃុំ | ៖ កោះស្នែង |
| ស្រុក | ៖ បុរីអូរស្វាយសែនជ័យ |
| ខេត្ត | ៖ ស្ទឹងត្រែង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

# កោះកន្ទាយ

# រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

| | |
|---|---|
| សហគមន៍នេសាទ | ៖ កោះកន្ទាយ |
| ភូមិ | ៖ ជាំធំ |
| ឃុំ | ៖ កោះស្នែង |
| ស្រុក | ៖ បុរីអូរស្វាយសែនជ័យ |
| ខេត្ត | ៖ ស្ទឹងត្រែង |

ខែមករា ឆ្នាំ២០១៩

## មាតិកា


**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម** ........ ២

ក.ប្រជាពលរដ្ឋ ........ ២

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក.ទីតាំង ........ ២

ខ. ដែននេសាទ ........ ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៤

ឃ.ធនធានជលផល ........ ៤

ឃ.១.ប្រភេទត្រី ........ ៤

ឃ.២.ប្រភេទវារីសត្វ ........ ៤

ឃ.៣.ប្រភេទសត្វបក្សី ........ ៤

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ........ ៤

**៤.ការធ្វើនេសាទ** ........ ៤

ក.អ្នកនេសាទ ........ ៤

ខ.ឧបករណ៍នេសាទ ........ ៤

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៦

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទស្សនវិស័យ ........ ៦

ខ. គោលបំណងរួម ........ ៦

គ.គោលបំណងជាក់លាក់ ........ ៦

ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៦

ឃ.១.ធនធានជលផល និងអេកូឡូស៊ី ........ ៦

ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៦

ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ........ ៧

ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ៧

ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៨

ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........ ៨

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល ........ ៨

ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ៩

ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ........ ៩

ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ........ ១០

ឃ.៣. ការងារគ្រប់គ្រង ........ ១០
ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........ ១០
ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ........ ១១
ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ........ ១២
ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១២
ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១២
ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១៣
ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖ ........ ១៣
ច.យុទ្ធសាស្ត្រ ........ ១៣
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះកន្ធាយ រយៈពេល៣ឆ្នាំ** (**២០២០ ដល់ ២០២២**) ........ ១៥
**តារាងកម្មវិធីការងារប្រចាំឆ្នាំ រយៈពេល៣ឆ្នាំ** (**២០១៩ - ២០២២**) ........ ២១

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទកោះកន្ទាយ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០០៦ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រយៈពេល៣ ឆ្នាំ គឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ សហគមន៍នេសាទកោះកន្ទាយ មានទីតាំងស្ថិតនៅក្នុងភូមិកោះជាំធំ ឃុំកោះស្នែង ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន ៣០៩ នាក់ ស្ត្រីចំនួន១០១ នាក់ ស្មើនឹង១០៨ គ្រួសារ និងមានគណៈកម្មការចំនួន០៧នាក់ ស្ត្រីចំនួន០៤នាក់។ សហគមន៍នេសាទកោះកន្ទាយ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមកសហគមន៍នេសាទ បានអនុវត្តសកម្មភាពសំខាន់ៗ មានដូចជាការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ការរៀបចំក្រុមល្បាត ព្រមទាំងចូលរួមប្រជុំ ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលាផ្សេងៗ រៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ចុះល្បាតតាមដែននេសាទជាប្រចាំ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងគឺៈ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមាន៖ ព្រៃលិចទឹកដួលរលំច្រើនដោយសារកំលាំងទឹកហូរបុកខ្លាំង បាក់ច្រាំងមាត់ទន្លេ ទិន្នផលត្រីថយចុះគ្រប់ប្រភេទត្រី មានការនេសាទនៅរដូវត្រីពងកូន និងកំណើនអ្នកនេសាទមកពីខាងក្រៅសហគមន៍ច្រើន

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត នៅឆ្ងាយពីទីផ្សារ ប្រជាជនចំណាកស្រុកច្រើន អ្នកនេសាទពីខាងក្រៅកើនឡើង ខ្វះប្រភពទឹកធ្វើស្រែ ភ្លៀងមិនគ្រប់គ្រាន់ ខ្វះចំណេះដឹង និងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ និងដំណាំផ្សេងៗ ទិន្នផលទាប ផលិតបានតិចតួចលក់ឲ្យតែគ្នាឯងក្នុងភូមិ (បន្លែ) តម្លៃផល ផលិតផលមិនស្ថិតស្ថេរ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងរួមមាន ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់ឧបករណ៍ឆក់ និងសារជាតិពុល គប់គ្រាប់ ដាក់មងក្នុងអន្លង់អភិរក្ស) ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធមិនទាន់រលូន ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ មិនមានការលើកទឹកចិត្តដល់គណៈកម្មការសហគមន៍នេសាទ ខ្វះមធ្យោបាយ និងថវិកាចុះល្បាត គ្មានទីស្នាក់ការសហគមន៍សម្រាប់បម្រើការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួន ហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ស្តីពីជលផល លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ការចូលរួមរបស់ប្រជាពលរដ្ឋមិនបានផុសផុល សហគមន៍នៅតែគិតថាការងារគណៈកម្មការជាការងារបច្ចេកទេស និងជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារការងារផ្ទះ និងលក់ដូរ និងការចូលរួមរបស់ស្ត្រីក្នុងកិច្ចប្រជុំនានាមានចំនួនច្រើន តែការសម្រេចចិត្តនៅមានកម្រិត។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងសហគមន៍កោះកន្ទាយ ភូមិជាំធំ មានចំនួនសរុប៥៦១នាក់ ស្ត្រី១៣២នាក់ ស្មើ ១៣០គ្រួសារ ចំនួនខ្នងផ្ទះ៨៤ខ្នងផ្ទះ ក្នុងនោះមានជនជាតិខ្មែរចំនួន១០០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន១០០%។

ប្រជាពលរដ្ឋក្នុងភូមិជាំធំ មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីជាមេគ្រួសារ/ស្ត្រីមេម៉ាយមាន ០៨នាក់
- ចំនួនបុរសពោះមាយមាន ០២នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន០២នាក់ ស្រី ០២នាក់
- ចំនួនចាស់ជរាមាន ០៣នាក់ ស្ត្រី០៣នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន១៤៥នាក់ ស្រី៨៦នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន៩០នាក់ ស្ត្រី៤៣នាក់ កម្រិតអនុវិទ្យាល័យចំនួន០នាក់។

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន៧៧គ្រួសារ
- អ្នកធ្វើស្រែចំនួន៣៥គ្រួសារ ដែលមានទំហំដីចំនួនសរុប ២៦ ហិកតា
- ធ្វើចំការចំនួន៤០ គ្រួសារ ដែលមានទំហំដីចំនួនសរុប៣៧ហិកតា (ស្រូវ.ពោត.សណ្តែក.)
- ដាំបន្លែជាលក្ខណៈគ្រួសារ១៣០គ្រួសារ (សួនជាលក្ខណៈគ្រួសារដែលមានទំហំ ៣ x ៤ ម៉ែត្រ)
- ជាងផ្ទះ ០៤គ្រួសារ
- លក់ដូរជាអាជីពចំនួន ០៤ គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ១៣០ គ្រួសារ ស្មើ ១០០%
- ជាងទូក ០៣គ្រួសារ
- ពេទ្យសត្វ ០១ គ្រួសារ
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួន១៣០ គ្រួសារ ក្នុងនោះរួមមានប្រហុក ត្រីប្រែ (មួយគ្រួសារអាចផលិតបានពី៥ គីឡូក្រាមទៅ ២០គីឡូក្រាមក្នុង១ឆ្នាំ)។

## ៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក.ទីតាំង

កន្លែងនេសាទសហគមន៍កោះកន្ទាយ ជាដែននេសាទសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍កោះកន្ទាយមានទំហំ ១.១៩៥ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**មានព្រំប្រទល់៖**

- ខាងជើងទល់នឹង កន្ទុយអន្លង់អូរតាឡាស ជាប់នឹងភូមិក្រឡាពាស ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ
- ខាងត្បូងទល់នឹង អូរព្រីងជាប់ព្រំប្រទល់សហគមន៍នេសាទភូមិកោះស្នែង ឃុំកោះស្នែង
- ខាងកើតទល់នឹង ពាក់កណ្តាលទន្លេជាប់សហគមន៍ភូមិកោះគី ឃុំកោះស្នែង ស្រុកបុរីអូរស្វាយសែនជ័យ

- ខាងលិចទល់នឹង ភូមិជាំធំ ឃុំកោះស្នែង ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។

**ខ. ដែននេសាទ**

កន្លែងសហគមន៍នេសាទកោះកន្ទាយ មានវិសាលភាពនៅក្នុងទន្លេមេគង្គ ហើយមានប្រឡាយចំនួន១០ អូរចំនួន០៥ កោះចំនួន០៤ និងអន្លង់ចំនួន០៣។

**ខ.១.ទន្លេ**

| ឈ្មោះទន្លេ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ១០.០០០ | ពេញមួយឆ្នាំ |

**ខ.២.ប្រឡាយ**

| ឈ្មោះអូរ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ប្រឡាយណាំជីវ | ២០០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយកំបោរតូច | ២០០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយរោងសេះ | ២០០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយកំបោរធុត | ១៥០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយអូរល្វា | ១០០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយតាប៊ុន | ២០០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយតារី | ៥០០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយសង្កែ | ២០០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយបងម៉ាប់ | ៥០ | ខែ០៨ ដល់ខែ១១ |
| ប្រឡាយល្វា | ៥០ | ខែ០៨ ដល់ខែ១១ |

**ខ.៣.កោះ**

| ឈ្មោះកោះ | ទទឹង និងបណ្តោយ(ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កោះតាឃុន | ២៥ × ២៥ | 0.១៣ |
| កោះជ្រូក | ៤០ × ១០០ | 0.៤០ |
| កោះក្រពើ | ៥០ × ១០០ | 0.៥០ |
| កោះកន្ទាយ | ១៥ × ៤០ | 0.0៦ |

**ខ.៤.អន្លង់**

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវវស្សា (ម៉ែត្រ) |
| អន្លង់កំបោរធុត | ប: ៣០ x ទ: ៣០ | ៩០០ | ៦០ | ៥០ |
| អន្លង់កំបោ | ប: ១៥០ x ទ:១០០ | ១៥.០០០ | ៤០ | ៣០ |
| អន្លង់កោះកន្ទាយ | ប: ៣០០ x ទ:១៥០ | ៤៥.០០០ | ២៥ | ១៥ |

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន១ អន្លង់ គឺកោះកន្ទាយ តាមការសម្រេចមហាសន្និបាត។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់កោះកន្ទាយ | ប: ៣០០ x ទ:១៥០ | ៤៥.០០០ | ២៥ | ១៥ |

**ឃ.ធនធានជលផល**

**ឃ.១.ប្រភេទត្រី៖**

ត្រីរស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ច្រវ៉ា កំភ្លាញ ឆ្ពួញ ខ្មាន់ ឆ្កិន ច្រកែង កន្ត្រប់ ត្រីដំរី កញ្ចុះ ក្រុះ កញ្ជ្រូក កាក្រហែរ ត្រីលិញ ទ្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឬស្សី ត្រីខ្នងត្រីខ្យា ត្រីកេះ ឆ្ពោក ត្រីកែ ត្រីក្រសក់ ត្រីអណ្តែង ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីឆ្មា ត្រីរាហ៊ូ ត្រីក្របី ត្រី ត្រីឬសចេក ត្រីក្អុក ត្រីគ្រំ ត្រីកំបុតច្រមុះ ត្រីខ្យាថ្ម ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ា ត្រីអន្ទង ត្រីអាចម៍កុក...។

**ឃ.២.ប្រភេទវារីសត្វ៖**

ក្តាម ខ្យង ខ្ចៅ គ្រុម លៀស ពស់ កំពិស កង្កែប ហ៊ីង គីង្គក់...។

**ឃ.៣.ប្រភេទសត្វបក្សី**

កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ រនាលខ្យង ក្អែកទឹក ក្អែកគោក...។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖**

ដើមគ្រែង ដើមអញ្ចោង ដើមរំចេក ដើមអណ្តែង ដើមក្រស់ ដើមរាំង ដើមល្វា ដើមផ្ចាទឹក ដើមក្តុល ដើមជ្រៃ....។

## ៤.ការធ្វើនេសាទ

**ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២១៦នាក់ ស្រី៩១នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន ២០ នាក់ ស្ត្រី៨ នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៤០ នាក់ស្រី១៦ នាក់។

**ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ អ្នកមិនចូលជាសមាជិក និងអ្នកនេសាទមកពីក្រៅសហគមន៍៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ / ប្រវែង | | | រដូវប្រើប្រាស់ ឧបករណ៍ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាងក្រៅ ភូមិ | |
| មង | ម៉ែត្រ | ៩២គ្រួសារ× ២×១០០ម = ១៨.៤០០ម | គ្មាន | ២៥គ្រួសារ× ១០×៧០ម= ១៧.៥០០ម | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | គ្មាន | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ៩២គ្រួសារ× ១វង់=៩២វង់ | គ្មាន | ១០គ្រួសារ× ១វង់=១០វង់ | ក្រឡា១,៥-៧ ស.ម សំរុង | គ្មាន | ក្រឡា១,៥-៧ស.ម សំរុង | ពេញមួយឆ្នាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | ៣,៥-៥.៥ម | | ៣,៥-៥.៥ម | |
| សន្ទូច | ផ្លែ | ៧៧គ្រួសារ× ១០០ផ្លែ = ៧.៧០០ផ្លែ | គ្មាន | ២៥គ្រួសារ× ៣០០ផ្លែ =៧.៥០០ផ្លែ | ផ្លែលេខ ១២-៥ | គ្មាន | ផ្លែលេខ ១២-៥ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ៣៥គ្រួសារ× ៣គ្រឿង =១០៥គ្រឿង | គ្មាន | គ្មាន | មុខកាត់ ០,៣០ម ប្រវែង១ម | គ្មាន | គ្មាន | វស្សា |
| ចាន់ | គ្រឿង | ៣៥គ្រួសារ×៥ គ្រឿង=១៧៥ គ្រឿង | គ្មាន | គ្មាន | មុខកាត់ ៤០ស.ម ប្រវែង១,៣ម | គ្មាន | គ្មាន | វស្សា |
| សៃយ៉ឺន | គ្រឿង | ៧គ្រួសារ× ៣គ្រឿង =២១គ្រឿង | គ្មាន | គ្មាន | មុខកាត់៥០ ស.ម ប្រវែង ២,៥ម | គ្មាន | គ្មាន | វស្សា |
| ឈ្នាងត្រាំ | គ្រឿង | ២គ្រួសារ× ២=០៤ គ្រឿង | គ្មាន | គ្មាន | មុខកាត់៧០ ស.ម ប្រវែង ៧០ស.ម | គ្មាន | គ្មាន | វស្សា |
| ស្នាង | គ្រឿង | ១០គ្រួសារ× ៥=៥០គ្រឿង | គ្មាន | គ្មាន | មុខកាត់១ម ប្រវែង៥ម | គ្មាន | គ្មាន | វស្សា |

ប្រភេទទូកកាណូត

| ប្រភេទកាណូត | ចំនួន | | | ចំណុះ (គីឡូក្រាម) | | | កំលាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ៥ | ១៣ | ០ | ១៥០-២០០ | ២០០-៣០០ | ០ | ៥,៥០ | ៦,៥០ | ០ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ១៥ | ៧ | ០ | ២០០-៣០០ | ២០០-៣០០ | ០ | ៦,៥០ | ៥,៥០ | ០ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ១០ | ០ | ០ | ៣០០-៤០០ | ០ | ០ | ៨ | ០ | ០ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ៥០ | ០ | ០ | ៣០០-៤០០ | ០ | ០ | ៩ | ០ | ០ |
| ទូកអេរជាប់ម៉ាស៊ីន HONDA | ៥០ | ០ | ០ | ៤០០-៥០០ | ០ | ០ | ១៣ | ០ | ០ |

គ.ប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |
| សរុប | | | **១.៦៦១,០៥** |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនវិស័យ

សហគមន៍នេសាទកោះកន្ទាយ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនៈវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ ។

### គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹក ក្នុងរដូវជំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ឃ.១.ធនធានជលផល និងអេកូឡូស៊ី

### ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺគិតគូរអំពីដែននេសាទ ប្រភេទឧបករណ៍នេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ក្នុងទន្លេមេគង្គកន្លែងសហគមន៍នេសាទកោះកន្ទាយ | នេសាទពេញ១ឆ្នាំជាលក្ខណៈគ្រួសារ | មង | ១០០ម៉ែត្រ/គ្រួសារ | ៩២គ្រួសារ | សមាជិក |
| | | សំណាញ់ | ១វង់/គ្រួសារ | ៩២គ្រួសារ | សហគមន៍ |
| | | សន្ទូច | ១០០ផ្លែ/គ្រួសារ | ៧៧គ្រួសារ | អ្នកនេសាទ |
| | | លប | ៣គ្រឿង/គ្រួសារ | ៣៥គ្រួសារ | ខាងក្នុង និង |

| | | | | | |
|---|---|---|---|---|---|
| | | ចាន់ | ៣គ្រឿង/គ្រួសារ | ៣៥គ្រួសារ | អ្នកនេសាទខាងក្រៅ |
| | | សៃយ៉ឺន | ៣គ្រឿង/គ្រួសារ | ៧គ្រួសារ | |
| | | ស្វាង | ៥គ្រឿង/គ្រួសារ | ១០គ្រួសារ | |
| ប្រឡាយណាំដីវ<br>ប្រឡាយកំបោរតូច<br>ប្រឡាយរោងសេះ<br>ប្រឡាយកំបោរធុត<br>ប្រឡាយអូរល្វា<br>ប្រឡាយតាប៉ិន<br>ប្រឡាយតារី<br>ប្រឡាយសង្កែ | ខែ០៨ ដល់ខែ១១ | មង | ១០០ម៉ែត្រ/គ្រួសារ | ៩២គ្រួសារ | សមាជិកសហគមន៍នេសាទកោះកន្ទាយ |
| | | សំណាញ់ | ១វង់/គ្រួសារ | ៩២គ្រួសារ | |
| | | សន្ទូច | ១០០ផ្លែ/គ្រួសារ | ៧៧គ្រួសារ | |
| | | លប | ៣គ្រឿង/គ្រួសារ | ៣៥គ្រួសារ | |
| | | ចាន់ | ៣គ្រឿង/គ្រួសារ | ៣៥គ្រួសារ | |
| | | សៃយ៉ឺន | ៣គ្រឿង/គ្រួសារ | ៧គ្រួសារ | |
| | | ស្វាង | ៥គ្រឿង/គ្រួសារ | ១០គ្រួសារ | |

### ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍កោះកន្ទាយ | បង្គោលព្រំធ្វើពីស៊ីម៉ងត៍ចំនួន៨បង្គោល | -ផលិតបង្គោលព្រំ<br>-រៀបចំក្រុមចុះបោះបង្គោលព្រំ | ២.០០០ | -គណៈកម្មការ<br>-សមាជិក<br>-មេភូមិ | ២០២០ | ២០២២ |
| | ផ្ទាំងប៉ាណូផែនទីធ្វើពីដែក១ផ្ទាំង | -ផលិតផ្ទាំងប៉ាណូផែនទី<br>-ចុះបោះផ្ទាំងប៉ាណូផែនទី | ២៥០ | គណៈកម្មការ | ២០២០ | ២០២០ |

### ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ | ទំហំហិកតា | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់កោះកន្ទាយ | ៤៥ | - ត្រីមេពូជ<br>- សត្វស្លាប<br>- ព្រៃលិចទឹក | - ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងសារៈប្រយោជន៍កន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្សចំនួន៤ទង់<br>- ដាក់ផ្លាកនៅអន្លង់អភិរក្ស<br>- ដាក់ផ្លាកប៉ាណូផែនទីអន្លង់អភិរក្ស<br>- ចុះល្បាតការពារជាប្រចាំ | ៦៧០ | ២០២០ | ២០២២ |

### ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ ហិកតា | ប្រភេទកូនឈើ ត្រូវការពារ | សកម្មភាព | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| នៅក្នុងដែនសហគមន៍នេសាទកោះកន្ទាយ | ៥០០ | ព្រៃលិចទឹកចម្រុះ | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ចុះល្បាតការពារជាប្រចាំ | ៤៥០ | ២០២០ | ២០២២ |

### ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទ/បរិមាណ | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន២០គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | ពូជមាន់ក្នុងស្រុក ២០គ្រួសារ | ២០x៣០០= ៦.០០០ | ២០២០ | ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន៣០គ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសកសិករ<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | ពូជក្នុងស្រុក ៣០គ្រួសារ | ៣០x៣០០= ៩.០០០ | ២០២០ | ២០២២ |
| បង្កើតធនាគារក្របីចំនួន ១០ គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍ក្រុម<br>- ជ្រើសរើសគ្រួសារ និងផ្តល់មេក្របី<br>- តាមដានត្រួតពិនិត្យការថែទាំ | ៤ក្បាល/៥ គ្រួសារ | ៣.០០០ | ២០២០ | ២០២២ |
| ចិញ្ចឹមគោនិងក្របីលក្ខណៈគ្រួសារចំនួន ២០គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំក្រោលសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | ពូជក្នុងស្រុក ២០គ្រួសារ | ២០x៣០០= ៦.០០០ | ២០២០ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| ដាំដំណាំបន្លែតាមបច្ចេកទេសកសិកម្មវ៉យឆ្លាតចំនួន១០គ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសកសិករ<br>- រៀបចំថ្នាលសម្រាប់បណ្តុះនិងដាំ<br>- បណ្តុះបណ្តាលបច្ចេកទេសដាំ<br>- រកទិញគ្រាប់ពូជសម្រាប់ដាំ<br>- តាមដានត្រួតពិនិត្យការថែទាំ | គ្រាប់បន្លែ៦ប្រភេទ ១០គ្រួសារ | ១០x៣០០=៣.០០០ | ២០២០ | ២០២២ |
| កែច្នៃផលិតផលនេសាទចំនួន១០គ្រួសារ | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំកន្លែងសម្រាប់កែច្នៃ<br>- បណ្តុះបណ្តាលបច្ចេកទេស<br>- រកទីផ្សារសម្រាប់លក់ផលិតផល<br>- តាមដានត្រួតពិនិត្យការថែទាំ | ប្រហុក ផ្អក ត្រីប្រៃ...១០គ្រួសារ | ១០x៣០០=៣.០០០ | ២០២០ | ២០២២ |
| ២៥គ្រួសារបង្កើតក្រុមសន្សំប្រាក់ និងកែច្នៃផលនេសាទចំនួន១ក្រុម | - ផ្សព្វផ្សាយទស្សនៈក្រុមសន្សំ<br>- បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន លេខា និងហិរញ្ញឹក<br>- បង្កើតគោលការណ៍និងបទបញ្ញាផ្ទៃក្នុងរបស់ក្រុម<br>- ដាក់ប្រាក់សន្សំ តាមដានជាប្រចាំ | ២៥គ្រួសារ | ១.៥០០ | ២០២០ | ២០២២ |

### ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណកូនត្រី | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសលក្ខណៈគ្រួសារ (១០គ្រួសារ/ឆ្នាំ) | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំស្រះ ដាក់កូនត្រី<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>- ត្រួតពិនិត្យ ធ្វើសំណាក<br>-ស្វែងរកទីផ្សារលក់ត្រី | ១០ស្រះ ទំហំ៥ម× ១០ម | ១៥.០០០ ក្បាល/៥ គ្រួសារ | ១០×៣០០=៣.០០០ | ២០២០ | ២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| សាងសង់ឡជីវឧស្ម័នចំនួន១៥គ្រួសារ | ២.៥០០ | ២០២០ | ២០២២ |
| ផ្តល់ប្រព័ន្ធអគ្គិសនីពន្លឺព្រះអាទិត្យក្នុងសហគមន៍ចំនួន ៧៥គ្រួសារ | ៩.០០០ | ២០២០ | ២០២២ |
| ផ្តល់ធុងចម្រោះទឹកចំនួន ៥០គ្រួសារ | ២.៥០០ | ២០២០ | ២០២២ |

| | | | |
|---|---|---|---|
| សាងសង់ផ្លូវថ្មីពីវត្តទៅកំបោរចំនួន១ខ្សែ | ១០.០០០ | ២០២០ | ២០២២ |
| ដាក់លូកាត់ផ្លូវ៦កន្លែងចំនួន ៦កន្លែង | ១០.០០០ | ២០២០ | ២០២២ |
| សាងសង់បង្គន់អនាម័យចំនួន ១៣០បង្គន់ | ១០.០០០ | ២០២០ | ២០២២ |
| បុកអណ្តូងស្នប់ចំនួន ១០កន្លែង | ២០.០០០ | ២០២០ | ២០២២ |
| សាងសង់សាលារៀនថ្មចំនួន ១ខ្នង | ៣០.០០០ | ២០២០ | ២០២២ |
| ពុម្ពសម្រាប់ចាក់លូ(ធ្វើអាងស្តុកទឹក)ចំនួន ១ឈុត | ៥០០ | ២០២០ | ២០២២ |

### ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាពធន់ និងការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការ | ៣០០ | ២០២០ | ២០២២ |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | ២០០ | ២០២០ | ២០២២ |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | ១០០ | ២០២០ | ២០២២ |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | ១០០ | ២០២០ | ២០២២ |
| | វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយដល់សហគមន៍ និងអាជ្ញាធរ | ២០០ | ២០២០ | ២០២២ |
| | ចងក្រងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិជាបណ្តាញ | ២០០ | ២០២០ | ២០២២ |

### ឃ.៣. ការងារគ្រប់គ្រង

### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៣ដង/ខែ | ៥.២០០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | ២ដង/ខែ | | ២០២០ | ២០២២ |
| ប្រេងសម្រាប់ល្បាត | | ៦០លីត្រ/ខែ | | ២០២០ | ២០២២ |
| សេវាជួសជុល ថែទាំទូក និងម៉ាស៊ីន | | ២ ដង/ឆ្នាំ | | ២០២០ | ២០២២ |
| ផ្តល់សម្ភារៈល្បាត (១ ឈុត) | អាវពោង | ៧ អាវ | ១.០០០ | ២០២០ | ២០២២ |
| | អាវភ្លៀង | ៧ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ៤ គោម | | | |

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| | វិទ្យុទាក់ទង | ២ គ្រឿង | | | |
| | កែវយឺត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ២ គ្រឿង | | | |
| | អង្រឹង | ៧ អង្រឹង | | | |
| | តង់គ្របទូក(៤x៦) | ២ តង់ | | | |
| | សម្ភារៈត្រួតពិនិត្យទឹក | ១ កំប្លេ | | | |
| | ស្លាបចក្រ | ៤ គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ២ សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ សោរ | | | |
| ទិញទូកស្ពាច់ម៉ាស៊ីន | (២០-២៧ សេះ) | ២ គ្រឿង | ៣.០០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | ដីជាប់សាលាឆទាន | ១ កន្លែង | ៣.០០០ | ២០២០ | ២០២២ |

**ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ**

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទត្រូវបានរៀបចំដូចខាងក្រោមៈ

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/ខែ | ៣៦០ | ២០២០ | ២០២២ |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ១ដង/ខែ | ១៨០ | | |
| បណ្តុះបណ្តាលការរៀបចំរបាយការណ៍ កំណត់ហេតុ | ១ដង/ឆ្នាំ | ២០០ | | |
| បណ្តុះបណ្តាលការគ្រប់គ្រងថវិកា និងគ្រប់គ្រងបញ្ជីរស្មាម | ១ដង/ឆ្នាំ | ២៥០ | | |
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/ឆ្នាំ | ២០០ | | |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/ឆ្នាំ | ២០០ | | |
| បណ្តុះបណ្តាលអំពីជំនាញសម្របសម្រួល | ១លើក/ឆ្នាំ | ២០០ | | |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការ | ១លើក/ឆ្នាំ | ២០០ | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | ១លើក/ឆ្នាំ | ៦.០០០ | | |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| យុទ្ធនាការប្រមូលឧបករណ៍នេសាទខុសច្បាប់ | ១/ឆ្នាំ | ៣០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ | ២/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយច្បាប់ស្ដីពីជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ១/ឆ្នាំ | ៣០០ | ២០២០ | ២០២២ |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារៈប្រយោជន៍ធនធានជលផល | ១/ឆ្នាំ | ៣០០ | ២០២០ | ២០២២ |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១/ឆ្នាំ | ៣០០ | ២០២០ | ២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍ តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៣០០ | ២០២០ | ២០២២ | គណៈកម្មការសហគមន៍នេសាទ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | | ២០២០ | ២០២២ | គណៈកម្មការសហគមន៍នេសាទ |

### ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលភាគទាន ៥០០រៀល/ម្នាក់ | ២០២០ | ២០២២ | ៣៨ | |
| ភាគទានប្រចាំឆ្នាំពីសមាជិក | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំចំនួន ២.០០០/គ្រួសារ នៃសមាជិកសរុប ១០៨គ្រួសារ | ២០២០ | ២០២២ | ១៦២ | |
| ភាគទានពីអ្នកនេសាទខាងក្រៅសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅ១ថ្ងៃចំនួន៥ទូក(១០.០០០ រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ១.១២៥ | |

| | | | | |
|---|---|---|---|---|
| ភាគលាភពីក្រុមសន្សំប្រាក់ | ស្នើបដិភាគថវិកាពីក្រុមសន្សំប្រាក់ | ២០២០ | ២០២២ | ៧៥ |
| **សរុបថវិកាសហគមន៍មាន** | | | | ១.៤០០ |
| **ប្រាក់ចំណូលពីប្រភពផ្សេងៗ** (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | **១៥៦.៨៨០** |
| **សរុបប៉ាន់ប្រមាណតម្លៃ** | | | | **១៥៨.២៨០** |

## ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៣២០ | ២០២០ | ២០២២ | គណៈកម្មការសហគមន៍នេសាទ |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី និងអ្នកពាក់ព័ន្ធ | ៦០០ | ២០២០ | ២០២២ | គណៈកម្មការ សហគមន៍នេសាទ |

## ច.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា៖ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ

- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសង្កាត់
- ជ្រើសរើសស្ត្រីមេគ្រួសារ ជាសមាជិកចំនួនយ៉ាងតិច៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- កម្មករគ្មានជំនាញជាស្ត្រីសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធ
- អញ្ជើញស្ត្រីមេគ្រួសារ ស្ត្រីជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និង ចូលជាគណៈកម្មការរបស់សហគមន៍
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផល ប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះកន្ធាយ រយៈពេល៣ឆ្នាំ (២០២០ ដល់ ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១.ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទនិងបើកនេសាទ) | ១ដង×១០០×២លើក×៣ឆ្នាំ=៦០០ | -សហគមន៍នេសាទ<br>-រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | ផលិតបង្គោលព្រំធ្វើពីស៊ីម៉ង់ត៍ចំនួន៨បង្គោលដាក់នៅតាមព្រំប្រទល់ដែននេសាទ កោះឈើទាលតូច | - បង្គោលចំនួន៨ដើមត្រូវបានផលិតនិងបានបោះនៅតាមព្រំទល់<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ២.០០០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទីចំនួន១ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន៣ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍ | ២៥០ | | ២០២០ | ២០២២ | |
| ឃ.១.៣.ការកំណត់និងរៀបចំតំបន់អភិរក្សអន្លង់កោះកន្ធាយ | - ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងសារៈប្រយោជន៍កន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ផ្លាកនៅអន្លង់អភិរក្ស<br>- ដាក់ផ្លាកប៉ាណូផែនទីអន្លង់អភិរក្ស<br>- ចុះល្បាតការពារជាប្រចាំ | - ត្រី និងសត្វគ្រប់ប្រភេទ នឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងបានដឹងពីព្រំប្រទល់កន្លែងអភិរក្ស និងចូលអភិរក្ស | ៦៧០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០២០ | ២០២២ | |
| ឃ.១.៤.ផែនការគ្រប់គ្រងការការពារព្រៃលិចទឹក | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ព្រៃលិចទឹកកើនឡើងវិញ<br>ធនធានត្រីមានការកើនឡើងវិញ | ៤៥០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ<br>-សប្បុរសជន | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់ចំនួន២០គ្រួសារ | ៦.០០០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូកចំនួន៣០គ្រួសារ | ៩.០០០ | | ២០២០ | ២០២២ | |
| | បង្កើតធនាគារក្របី | សមាជិក១០ គ្រួសារចូលរួមបង្កើត | ៣.០០០ | | ២០២០ | ២០២២ | |
| | ចិញ្ចឹមគោនិងក្របីលក្ខណៈគ្រួសារ | មាន២០គ្រួសារចិញ្ចឹមគោ និងក្របី | ៦.០០០ | | ២០២០ | ២០២២ | |
